## រឿងទី៧៖ យ៉ូស្វេ

**ខគម្ពីរ៖ យ៉ូស្វេ៦៖២០**

... ហើយក្រុមបូជាចារ្យក៏ផ្លុំស្នែងដែរ។ កាលប្រជាជនឮស្នូរសំឡេងស្នែងគេនាំគ្នាស្រែកឡើងយ៉ាងខ្លាំង ពេលនោះកំពែងក្រុងក៏រលំចុះនៅនឹងកន្លែង...។

ម៉ូសេដែលបានដឹកនាំរាស្ត្រអ៊ីស្រាអែលចេញមកនោះ មុនពេលចូលទៅក្នុងទឹកដីកាណានគាត់ក៏ទទួលមរណៈភាព ពេលនោះព្រះជាម្ចាស់ក៏បានរើសតាំង «យ៉ូស្វេ»ជាអ្នកដឹកនាំថ្មីបន្ទាប់ពីលោកម៉ូសេ។

ព្រះជាម្ចាស់បានមានបន្ទូលថា ទ្រង់នឹងគង់ជាមួយយ៉ូស្វេ។

យ៉ូស្វេបានចាត់អ្នកស៊ើបការណ៍ពីរនាក់ឱ្យទៅសង្កេតមើលក្រុងយេរីខូរ

អ្នកស៊ើបការណ៍ពីរនាក់នោះ បានចូលទៅរស់នៅក្នុងផ្ទះរបស់ស្ត្រីម្នាក់ឈ្មោះរ៉ាហាប ដោយផ្ទះនាងគឺស្ថិតនៅលើជញ្ជាំងក្រុងយេរីខូរដូច្នេះ វាមានភាពងាយស្រួលក្នុងការសង្កេតមើលស្រុកបានយ៉ាងច្បាស់។

ស្តេចក្រុងយេរីខូបានដឹងដំណឹងថាមានអ្នកស៊ើបការណ៍សាសន៍អ៊ីស្រាអែលបានចូលមកក្នុងទឹកដីខ្លួនហើយ ខឹងសម្បារជាខ្លាំង ក៏ហៅពួកទាហានឱ្យចេញទៅចាប់ពួកអ្នកស៊ើបការណ៍ទាំងនោះ។ ប៉ុន្តែ នាងរ៉ាហាបបានជួយអ្នកស៊ើបការណ៍ទាំងនោះឱ្យរត់គេចខ្លួន។

រ៉ាហាបបានសុំឱ្យពួកគេទុកជីវិតឱ្យនាង និងគ្រួសារនាងផង ពេលពួកគេមកផ្តួលរំលំក្រុងយេរីខូ។

អ្នកស៊ើបការណ៍បានសន្យាជាមួយរ៉ាហាប ហើយក៏បានចាកចេញពីក្រុងយេរីខូដោយសុវត្ថិភាព។

ក្រោយពីប្រជារាស្ត្រអ៊ីស្រាអែលបានរស់នៅក្នុងទីវាលរហោស្ថានអស់រយៈពេលសែសិបឆ្នាំហើយនោះ ទីបំផុតពេលនេះ ពួកគេបានធ្វើដំណើរដល់ទន្លេយ័រដាន់ដែលនៅក្បែរស្រុកកាណាន ដែលព្រះជាម្ចាស់បានសន្យានោះហើយ។ ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់ ត្រូវតែឆ្លងទន្លេយ័រដាន់នោះសិនទើបអាចចូលទៅទឹកដីកាណានបាន។

ពេលនោះ ព្រះជាម្ចាស់បានមានបន្ទូលទៅយ៉ូស្វេថា៖ «ចូរប្រាប់ឱ្យបណ្តាជនបានដឹងទៅថា យើងជាព្រះនឹងគង់នៅជាមួយនិងអ្នក ដូចគង់នៅជាមួយនិងម៉ូសេដែរ! ចូរបង្គាប់ឱ្យពួកសង្ឃដែលសែងហិបនៃសេចក្តីសញ្ញាចូលទៅក្នុងទឹកទន្លេយ័រដានទៅ នោះទឹកទន្លេនឹងនៅនឹងថ្កល់»។



ពួកសង្ឃដែលសែងហិបនៃសេចក្តីសញ្ញាបានឈានជើងចូលទៅក្នុងទឹកទន្លេយ័រដាន់។



ពេលនោះកម្លាំងទឹកទន្លេយ័រដាន់ដែលហូរមកខ្លាំងនោះ ក៏រីងក្លាយជាដីគោក។
រាស្ត្រអ៊ីស្រាអែលបានដើរឆ្លងកាត់ទន្លេយ័រដាន់ដោយសុវត្ថិភាពដូចពួកបុព្វបុរសបានដើរឆ្លងកាត់សមុទ្រក្រហមដែរ។
ព្រះជាម្ចាស់បានមានបន្ទូលទៅយ៉ូស្វេដែលឈរនៅមុខក្រុងយេរីខូថា៖ «យើងនឹងប្រគល់ក្រុងយេរីខូរឱ្យដល់អ្នក។
ដូច្នេះត្រូវឱ្យអ្នករាល់គ្នាជាពួកថ្មីកច្បាំងដើរជុំវិញក្រុងអស់ប្រាំមួយថ្ងៃក្នុងមួយថ្ងៃមួយជុំ។
ពួកសង្ឃត្រូវផ្លុំត្រែស្នែងចៀម ចំណែកអ្នកផ្សេងទៀតមិនត្រូវឱ្យមានឮសម្លេងអ្វីទាំងអស់។
នៅថ្ងៃចុងក្រោយជាថ្ងៃទីប្រាំពីរ ត្រូវដើរជុំវិញក្រុងប្រាំពីរជុំ។
បន្ទាប់មកទៀតត្រូវឱ្យសង្ឃផ្លុំត្រែឱ្យឮសម្លេងវែងហើយត្រូវនាំគ្នាស្រែកឱ្យខ្លាំងសំដៅទៅក្រុងនោះ!
នោះ ក្រុងយេរីខូនឹងត្រូវដួលរលំជាមិនខាន។»
យ៉ូស្វេ និងប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់បានធ្វើតាមព្រះបន្ទូលព្រះជាម្ចាស់។
ភ្លាមនោះ ក្រុងយេរីខូក៏បានដួលរលំមែន។ ទីក្រុងក៏បានដួលរលំធ្វើឱ្យមនុស្សនៅក្នុងក្រុងនោះទាំងអស់បានបាត់បង់ជីវិត។
ប៉ុន្តែ អ្នកស៊ើបការណ៍បានទុកជីវិតឱ្យរ៉ាហាបនិងគ្រួសារនាងតាមការសន្យា។
ដោយព្រោះយ៉ូស្វេនិងប្រជារាស្ត្រ អ៊ីស្រាអែលទាំងអស់បានស្តាប់បង្គាប់ព្រះបន្ទូលព្រះជាម្ចាស់ ដូច្នេះ ពួកគេក៏បានចូលទៅរស់នៅក្នុងទឹកដីកាណានដែលជាទឹកដីសន្យារបស់ព្រះជាម្ចាស់។

- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (យ៉ូស្វេ៦៖២០)

គេនាំគ្នាស្រែកឡើងយ៉ាងខ្លាំង ពេលនោះកំពែងក្រុងក៏រលំចុះនៅនឹងកន្លែង។



**សកម្មភាពទី១** ចូរកាត់ និងបិទក្រដាសពណ៌តាមដំណើរការខាងក្រោម រួចតុបតែងក្រុងយើខ្ញុំ។ (សម្ភារៈ៖ ក្រដាសពណ៌, កន្ត្រៃ, កាវ)



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀនថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

